

ក្រសួងអប់រំរដ្ឋ NSW

# ការផ្លាស់ចូល Year 7 នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW

## ដាក់ពាក្យសុំតាមអនឡាញ ដើម្បីចាប់ផ្តើមការធ្វើអន្តរកាលកូនរបស់អ្នកពី Year 6 ទៅ Year 7។

### សាលារៀនក្នុងមូលដ្ឋានរបស់កូនអ្នក

សាលារៀនរដ្ឋក្នុងរដ្ឋ NSW ភាគច្រើន មានតំបន់ទទួលយកសិស្សដែលបានកំណត់ ដូច្នេះ កុមារដែលមានអាយុចូលរៀនទាំងអស់ នឹងមានសិទ្ធិចូលរៀននៅសាលារៀនរដ្ឋមួយ - ដែលជាសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេ។

អាសយដ្ឋានលំនៅដ្ឋានអចិន្ត្រៃយ៍របស់កូនអ្នក កំណត់ពីសាលារៀនមួយណា ជាសាលារៀនក្នុងមូលដ្ឋានរបស់កូនអ្នក។ ឧបករណ៍ស្វែងរកសាលារៀន (School Finder) នៅតាមគេហទំព័រ [education.nsw.gov.au/school-finder](education.nsw.gov.au/school-finder) អាចជួយអ្នកស្វែងរកទីតាំងសាលារៀនក្នុងមូលដ្ឋាន។

ឪពុកម្តាយ និងអ្នកថែទាំភាគច្រើនក្នុងរដ្ឋ NSW ជ្រើសរើសសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេ ដើម្បីផ្តល់ការអប់រំយ៉ាងឧត្តមសម្រាប់កូនរបស់ពួកគេ។ ប្រព័ន្ធចុះឈ្មោះចូលរៀនតាមអនឡាញរបស់ក្រសួង គាំទ្រដល់ការធ្វើអន្តរកាលទៅសាលាមធ្យមសិក្សា។

សាលារៀនក្នុងមូលដ្ឋាន បំពេញបំណងសិស្សគ្រប់កម្រិតសមត្ថភាព រួមទាំងកម្មវិធីនានា ដើម្បីជម្រុញសិស្សដែលមានសក្តានុពល និងនិស្ស័យខ្ពស់ ហើយនិងកម្មវិធីសម្រាប់សិស្សដែលមានតម្រូវការរៀនសូត្រ និងការគាំទ្របន្ថែម។ សាលារៀនទាំងនេះ ក៏ផ្តល់ជូនសកម្មភាពក្រៅកម្មវិធីសិក្សាជាច្រើនផងដែរ។

មានវិទ្យាល័យពហុសាខា ដែលរួមមានសាលារៀន ឬសាខាមួយចំនួនដែលសាលារៀន ឬសាខានីមួយៗទាំងនោះមានឯកទេសក្នុងវិស័យផ្សេងៗគ្នា។ ឧទាហរណ៍ មានវិទ្យាល័យជាន់ទាប (Years 7-9 ឬ 7-10), វិទ្យាល័យជាន់ខ្ពស់ (Years 10-12 ឬ 11-12), វិទ្យាល័យសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា សាខាសម្រាប់សិស្សទាំងពីរភេទ និងសាខាសម្រាប់សិស្សតែមួយភេទ។

ក៏មានសាលាកណ្តាលផងដែរ ដែលផ្តល់ជូនសហគមន៍ជនបទ និងតំបន់ដាច់ស្រយាលជាច្រើននូវឱកាសអប់រំកូនៗរបស់ពួកគេ ចាប់ពីថ្នាក់ Kindergarten ទៅដល់ Year 12 នៅក្នុងទីតាំងសាលារៀនតែមួយ។ សាលាកណ្តាលជាច្រើន ប្រើប្រាស់បច្ចេកវិទ្យាដើម្បីភ្ជាប់គ្រូបង្រៀន និងសិស្សនៅតាមសាលារៀនខុសៗគ្នា ដើម្បីផ្តល់ជូនមុខវិជ្ជាជាច្រើន។ សាលាកណ្តាលក៏ផ្តល់ជូនសកម្មភាពក្រៅកម្មវិធីសិក្សាយ៉ាងទូលំទូលាយផងដែរ។

ប្រសិនបើអ្នកមិនអាចដាក់ពាក្យសុំអនឡាញបានទេ ឬអ្នកមិនចង់ សូមបំពេញទម្រង់បែបបទដែលចាប់ផ្តើមនៅទំព័រ 5 នៃកូនសៀវភៅនេះ។ ប្រគល់ទម្រង់បែបបទដែលបានបំពេញរួចហើយ ទៅសាលាបឋមសិក្សារបស់កូនអ្នក។

ព័ត៌មានបន្ថែមអាចរករបាននៅតាមគេហទំព័រ [education.nsw.gov.au/public-schools/going-to-a-public-school/enrolment/high-school-enrolment](education.nsw.gov.au/public-schools/going-to-a-public-school/enrolment/high-school-enrolment)

NSW GOVERNMENT

# ជម្រើសសាលារៀនផ្សេងទៀត

## អ្នកអាចមានហេតុផលនានា ដែលអ្នកចង់ឱ្យកូនរបស់អ្នកទៅសាលារៀន ដែលមិនមែនជាសាលារៀនក្នុងមូលដ្ឋានរបស់អ្នក។



### សាលារៀនក្រៅមូលដ្ឋាន (ឬក្រៅតំបន់)

សាលារៀនដែលមានតំបន់ទទួលយកសិស្សដែលបានកំណត់ មានកម្រិតការចុះឈ្មោះចូលរៀន - ចំនួនសិស្សដែលអាចចុះឈ្មោះចូលរៀន គឺផ្អែកលើទីកន្លែងស្នាក់នៅអចិន្ត្រៃយ៍របស់សាលារៀននោះ។ កម្រិតការចុះឈ្មោះចូលរៀន ប្រាប់យើងថាតើសាលារៀនអាច ឬក៏មិនទទួលយកការចុះឈ្មោះក្រៅមូលដ្ឋាន។ នៅក្នុងកម្រិតការចុះឈ្មោះចូលរៀន សាលារៀនមួយចំនួនបានកំណត់កម្រិតការចុះឈ្មោះក្នុងមូលដ្ឋាន ដើម្បីរក្សាទុកកន្លែងសម្រាប់សិស្សមូលដ្ឋានដែលមកដល់ក្នុងអំឡុងឆ្នាំនោះ។

សាលារៀនដែលមានចំនួនលើស ឬខិតជិតដល់កម្រិតការចុះឈ្មោះចូលរៀនរបស់ពួកគេ នឹងមិនចុះឈ្មោះសិស្សក្រៅមូលដ្ឋានទេ លើកលែងតែមានកាលៈទេសៈពិសេសនានា។

ទោះយ៉ាងណាក៏ដោយ សាលារៀនដែលមានកន្លែងចុះឈ្មោះនៅក្រោមកម្រិតនេះ អាចទទួលយកសិស្សក្រៅមូលដ្ឋានបាន។

នៅសាលារៀនដែលមានតម្រូវការចុះឈ្មោះក្រៅមូលដ្ឋាន លើសពីចំនួនកន្លែងដែលមាននៅក្រោមកម្រិត សាលារៀននោះត្រូវបង្កើតលក្ខណៈវិនិច្ឆ័យចុះឈ្មោះក្រៅតំបន់ ហើយបង្កើតក្រុមជ្រើសរើសមួយ ដើម្បីពិចារណាលើពាក្យសុំក្រៅមូលដ្ឋាន។

### សាលាឯកទេស

សាលាឯកទេសផ្តល់ជូនការអប់រំកម្រិតមធ្យមសិក្សា ដែលផ្តោតលើទេពកោសល្យ ឬចំណាប់ចំណូលចិត្តជាក់លាក់។ សាលាឯកទេសត្រូវបានបង្កើតឡើងសម្រាប់សិល្បៈច្នៃប្រឌិត សិល្បៈសម្តែង សិល្បៈដែលមើលឃើញ ភាសា បច្ចេកវិទ្យា (រួមមានបច្ចេកវិទ្យាផ្នែកសមុទ្រ និងបច្ចេកវិទ្យាផ្នែកជនបទ) កសិកម្ម និងកីឡា។

នៅតាមសាលាឯកទេសមួយចំនួន លក្ខណៈវិនិច្ឆ័យក្នុងការចុះឈ្មោះចូលរៀនអាចមានរួមទាំងការសម្តែង ឬការសម្តែងបង្ហាញទេពកោសល្យមុនពេលទទួលយក។

### ថ្នាក់គាំទ្រ

សាលាមធ្យមសិក្សាមួយចំនួនមានថ្នាក់គាំទ្រដើម្បីបំពេញតម្រូវការសិក្សា និងការគាំទ្របន្ថែមរបស់សិស្សដែលមានពិការភាព។ នាយកសាលាបឋមសិក្សារបស់កូនអ្នក នឹងជួយអ្នកស្វែងរកជម្រើសសិក្សាត្រឹមត្រូវសម្រាប់កូនរបស់អ្នក ដោយគិតគូពីជម្រើសរបស់អ្នក តម្រូវការសិក្សាបន្ថែមជាក់លាក់របស់កូនអ្នក និងការនៅជិតទីកន្លែងសេវាកម្មសាលាឯកទេសក្នុងមូលដ្ឋាន។

ការពិចារណាសម្រាប់ការផ្តល់ទីកន្លែងរៀនក្នុងថ្នាក់គាំទ្រ ត្រូវបានគ្រប់គ្រងតាមរយៈដំណើរផ្តល់ទីកន្លែងរៀន។

### សាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា

ដំណើរការដាក់ពាក្យសុំចូលរៀននៅសាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សាទាំងស្រុង ឬផ្នែកសិក្សាខ្លះ ចាប់ផ្តើមនៅពេលសិស្សរៀននៅ Year 5 ហើយមានដំណើរការវែងជាងដំណើរការដាក់ពាក្យសុំចូលរៀនតាមធម្មតា។

ទម្រង់ពាក្យសុំមានផ្តល់ជូននៅតាមអនឡាញតែប៉ុណ្ណោះ។ សូមកត់ចំណាំថា ពាក្យសុំដែលបានដាក់យឺតយ៉ាវនឹងមិនទទួលយកឡើយ។

បញ្ជីឈ្មោះសាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា និងព័ត៌មានលម្អិតអំពីនីតិវិធីចុះឈ្មោះចូលរៀនរបស់ពួកគេ អាចរកបាននៅតាមគេហទំព័រ https://education.nsw.gov.au/public-schools/selective-high-schools-and-opportunity-classes

### មជ្ឈមណ្ឌលសិក្សាភាសាអង់គ្លេសសកម្ម

ប្រើឧបករណ៍ស្វែងរកសាលារៀននៅតាមគេហទំព័រ https://education.nsw.gov.au/school-finder ដើម្បីកំណត់ទីតាំងសាលាមធ្យមសិក្សាដែលផ្តល់ការផ្តត់ផ្តង់ភាសាអង់គ្លេសសកម្ម។

ផ្តល់អាសយដ្ឋានផ្ទះរបស់អ្នក ឬលេខកូដប្រៃសណីយ៍ ដើម្បី ស្វែងរកផែនទីសាលារៀនក្នុងមូលដ្ឋានរបស់អ្នក រួចចុចប៊ូតុង Intensive English Centre នៅលើ “Nearby schools”។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកសាលាបឋមសិក្សាក្នុងមូលដ្ឋានរបស់អ្នក ឬសាលាមធ្យមសិក្សាដែលជាជម្រើសរបស់អ្នក។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក**សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ** លេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

# ការបំពេញទម្រង់បែបបទការបង្ហាញចំណាប់អារម្មណ៍

## អ្នកអាចចង្អុលបង្ហាញសាលារៀនមួយណាដែលអ្នកចង់ឱ្យកូនរបស់អ្នកចូលរៀន ដោយបំពេញទម្រង់បែបបទការបង្ហាញចំណាប់អារម្មណ៍ សម្រាប់សាលារៀនក្នុងមូលដ្ឋានរបស់អ្នក និង/ឬសាលារៀនក្រៅតំបន់ចំនួន 3 អតិបរមា។

មានជំហានបីដើម្បីចុះឈ្មោះកូនរបស់អ្នកនៅ Year 7៖

## ជំហានទី 1: បំពេញការបង្ហាញចំណាប់អារម្មណ៍ ដើម្បីស្នើសុំទីកន្លែងរៀននៅសាលារៀនរដ្ឋដែលជាជម្រើសរបស់អ្នក។

### គួរបំពេញទម្រង់បែបបទនេះជាភាសាអង់គ្លេសដោយឪពុកម្ដាយ និងអ្នកថែទាំសិស្សទាំងអស់ ដែលស្នើសុំទីកន្លែងរៀនសម្រាប់ Year 7 នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ឆ្នាំក្រោយ។

សម្រាប់សិស្សដែលបានចុះឈ្មោះនៅសាលាបឋមសិក្សារដ្ឋក្នុងរដ្ឋ NSW នាពេលបច្ចុប្បន្ន អ្នកអាចបំពេញការបង្ហាញចំណាប់អារម្មណ៍តាមអនឡាញ ឬបំពេញទម្រង់បែបបទក្រដាសដែលភ្ជាប់មកជាមួយ ហើយប្រគល់វាទៅសាលាបឋមសិក្សារបស់កូនអ្នក។ សម្រាប់សិស្សដែលមិនបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សារដ្ឋក្នុងរដ្ឋ NSW អ្នកអាចបំពេញការបង្ហាញចំណាប់អារម្មណ៍តាមអនឡាញ ឬប្រគល់ទម្រង់បែបបទនេះទៅសាលាមធ្យមសិក្សារដ្ឋក្នុងរដ្ឋ NSW ដែលអ្នកមានបំណងចង់ចុះឈ្មោះកូនរបស់អ្នក។

**រាល់ការបង្ហាញចំណាប់អារម្មណ៍ទាំងអស់ត្រូវតែប្រគល់ឱ្យបានទាន់ ឬមុនកាលបរិច្ឆេទកំណត់។**

## ជំហានទី 2៖ បំពេញពាក្យសុំចុះឈ្មោះចូលរៀន

នៅពេលកូនរបស់អ្នកបានទទួលទីកន្លែងរៀននៅសាលា មួយហើយ អ្នកនឹងត្រូវបានស្នើសុំឱ្យបំពេញ**ពាក្យសុំចុះឈ្មោះចូលរៀន នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW**។ ពាក្យសុំនេះនឹងត្រូវបានផ្ញើជូនអ្នកក្នុងអំឡុងត្រីមាសទី 2 ឬត្រីមាសទី 3។

អ្នកអាចបំពេញពាក្យសុំតាមអនឡាញ ឬដោយបំពេញទម្រង់បែបបទក្រដាសដែលនឹងផ្ញើជូនអ្នកក្នុងអំឡុងត្រីមាសទី 2 ឬត្រីមាសទី 3។

សូមបំពេញព័ត៌មានលម្អិតទាំងអស់នៅលើទម្រង់បែបបទនេះ ហើយប្រគល់វាឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។

ការសម្រេចចិត្តចុងក្រោយអំពីការចុះឈ្មោះចូលរៀន នឹងត្រូវបានធ្វើឡើងដោយនាយកសាលា បន្ទាប់ពីមានការពិចារណា និងការទទួលយកពាក្យសុំចុះឈ្មោះចូលរៀនរបស់អ្នក។ នាយកសាលាអាចទាក់ទងមកអ្នកដើម្បីសួររកព័ត៌មានបន្ថែម។

អ្នកនឹងទទួលបានអ៊ីមែល ឬលិខិតមួយច្បាប់ ដើម្បីបញ្ជាក់ថាតើកូនរបស់អ្នកត្រូវបានទទួលយកការចុះឈ្មោះចូលរៀនឬអត់។

## ជំហានទី 3៖ ស្វែងយល់ពីសាលារៀនថ្មីរបស់អ្នក

នៅពេលអ្នកទទួលបានការបញ្ជាក់ពីការចុះឈ្មោះចូលរៀនរបស់ កូនអ្នកហើយ នេះគឺជាការសំខាន់ដែលត្រូវស្វែងយល់ពីសាលា រៀនថ្មីនោះដើម្បីគាំទ្រដល់ការផ្លាស់ចូល Year 7 របស់កូនអ្នក។

សាលារៀននឹងរៀបចំសកម្មភាពអន្តរកាលនានា និងទិវាណែនាំតម្រង់ទិសសម្រាប់សិស្សដែលនឹងចាប់ផ្ដើម Year 7 នៅឆ្នាំក្រោយ។ ឪពុកម្ដាយ និងអ្នកថែទាំ ជាទូទៅត្រូវបានអញ្ជើញឱ្យចូលរួមក្នុងទិវាណែនាំតម្រង់ទិសនេះ ដែលជាធម្មតាត្រូវបានធ្វើឡើងនៅចុងខែវិច្ឆិកា/ដើមខែធ្នូ។ វាជួយឱ្យកូនរបស់អ្នកស្វែងយល់អំពីមេរៀន និងមុខវិជ្ជានានានៅសាលាមធ្យមសិក្សា គ្រូបង្រៀន ថ្នាក់រៀន និងនីតិវិធីរបស់សាលារៀន ហើយផ្ដល់ឱកាសដើម្បីជួបជាមួយសិស្សឯទៀតផងដែរ។

អ្នកនឹងទទួលបានការជូនដំណឹង អំពីកាលបរិច្ឆេទនៃទិវាណែនាំតម្រង់ទិសពីសាលារៀនថ្មីរបស់អ្នក រួមជាមួយព័ត៌មានអំពីឯកសណ្ឋាន ជម្រើសនៃមធ្យោបាយធ្វើដំណើរ និងព័ត៌មានលម្អិតសំខាន់ៗផ្សេងទៀត។

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទមកនាយកសាលា។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយអ្នក សូមទូរសព្ទមកសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ លេខ **131 450** ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ការិទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

## ព័ត៌មានដែលនឹងជួយសាលារៀនថ្មីរបស់អ្នក ផ្ដល់ឱ្យកូនរបស់អ្នកនូវការរៀនសូត្រ និងការគាំទ្រ

ជាការសំខាន់ដែលអ្នកត្រូវផ្ដល់សាលារៀនថ្មីរបស់អ្នក នូវព័ត៌មានអំពីតម្រូវការសិក្សា និងការគាំទ្ររបស់កូនអ្នក។ នេះជាការសំខាន់ដែលអ្នកត្រូវប្រាប់សាលារៀនអំពីការទាស់នឹងធាតុអ្វីមួយ ឬស្ថានភាពសុខភាពផ្សេងទៀតដែលបានដឹង ទាក់ទិននឹងកូនរបស់អ្នក។

នេះរួមបញ្ចូល តែមិនកំណត់ចំពោះព័ត៌មានដែលកូនរបស់អ្នកត្រូវបានធ្វើរោគវិនិច្ឆ័យថាមានប្រតិកម្មអាណាហ្វីឡាក់ទិច (ការទាស់យ៉ាងធ្ងន់ធ្ងរ) ជំងឺហឺត ជំងឺទឹកនោមផ្អែម ឬជំងឺឆ្កួតជ្រូក។

ប្រសិនបើកូនរបស់អ្នកត្រូវបានធ្វើរោគវិនិច្ឆ័យ ថាមានហានិភ័យនៃប្រតិកម្មអាណាហ្វីឡាក់ទិច សូមផ្ដល់សាលារៀនថ្មីរបស់កូនអ្នកនូវផែនការព្យាបាលអាណាហ្វីឡាក់ទិចបច្ចុប្បន្ន គឺ ASCIA Action Plan for Anaphylaxis ដែលបានបំពេញ និងចុះហត្ថលេខាដោយវេជ្ជបណ្ឌិតរបស់កូនអ្នក។

រួមជាមួយផែនការ ASCIA Action Plan សាលារៀននឹងតម្រូវឱ្យមាន adrenaline autoinjector (ឧបករណ៍ចាក់ថ្នាំអាដ្រេណាលីន ស្វ័យប្រវត្តិ) ដើម្បីគាំទ្រដល់ការឆ្លើយតបផ្នែកសុខភាពបន្ទាន់ក្នុងផែនការនេះ។ សូមកត់សម្គាល់នូវកាលបរិច្ឆេទផុតកំណត់នៅលើ adrenaline autoinjector ដែលបានផ្ដល់ឱ្យសាលារៀន និងផ្ដល់ឧបករណ៍ថ្មីជំនួសឱ្យបានមុនពេល។

## ព័ត៌មានដើម្បីជួយអ្នកបំពេញការបង្ហាញចំណាប់អារម្មណ៍

### ផ្នែក A

សូមបំពេញព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់កូនអ្នក និងចុះហត្ថលេខាលើសេចក្ដីប្រកាសនៅ**ផ្នែក A**។

### ផ្នែក B

**ផ្នែក B** បង្ហាញឈ្មោះសាលារៀនក្នុងមូលដ្ឋានដែលបានកំណត់របស់អ្នក ដោយផ្អែកលើអាសយដ្ឋានផ្ទះរបស់កូនអ្នក។ កូនរបស់អ្នកមានសិទ្ធិទទួលបានទីកន្លែងមួយនៅសាលារៀនក្នុងមូលដ្ឋានរបស់ពួកគេ។

ប្រសិនបើអ្នកកំពុងស្វែងរកទីកន្លែងរៀន នៅសាលារៀនក្នុងមូលដ្ឋានរបស់អ្នកតែប៉ុណ្ណោះ សូមចុះហត្ថលេខានៅ**ផ្នែក B** ហើយប្រគល់ទម្រង់បែបបទឱ្យបានទាន់កាលបរិច្ឆេទកំណត់។ ឥឡូវនេះអ្នកបានបំពេញទម្រង់បែបបទរួចហើយ។

ប្រសិនបើអ្នកបានដាក់ពាក្យសុំចូលរៀន នៅសាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា ហើយអ្នកចង់ឱ្យកូនរបស់អ្នកទៅសាលារៀនក្នុងមូលដ្ឋាន ប្រសិនបើមិនបានជោគជ័យទេនោះ សូមចុះហត្ថលេខា និងចុះកាលបរិច្ឆេទនៅ**ផ្នែក B** ផងដែរ។

## ផ្នែក C

ប្រសិនបើអ្នកកំពុងស្វែងរកទីកន្លែងរៀនផ្សេងទៀត សូមរាយឈ្មោះសាលារៀន រហូតដល់បីកន្លែង តាមលំដាប់នៃចំណង់ចំណូលចិត្តនៅ**ផ្នែក C**។

អ្នកអាចស្នើសុំទីកន្លែងរៀននៅ៖

- សាលាឯកទេស
- ថ្នាក់គាំទ្រ (ដោយមានការពិគ្រោះយោបល់ជាមួយនាយកសាលាបឋមសិក្សារបស់អ្នក) ដែលនឹងដាក់ពាក្យស្នើសុំប្រភេទនៃថ្នាក់គាំទ្រ
- សាលារៀនក្រៅតំបន់។

**សូមកត់ចំណាំថាសាលាឯកទេស និងក្រុមផ្តល់ទីកន្លែងរៀនសម្រាប់ការចុះឈ្មោះចូលរៀននៅសាលារៀនក្រៅមូលដ្ឋាន នឹងមានតម្រូវការដាក់ពាក្យបន្ថែមទៀត។**

ប្រសិនបើអ្នកមិនប្រាកដថា អ្នកត្រូវការបំពេញទម្រង់បែបបទបន្ថែមណាមួយ សូមទាក់ទងដោយផ្ទាល់ជាមួយសាលារៀនដែលអ្នកចាប់អារម្មណ៍។

**មានជំហានបន្ថែមទៀត ប្រសិនបើអ្នកកំពុងស្នើសុំទីកន្លែងរៀននៅសាលារៀនក្រៅតំបន់។**

**សាលារៀននានាមានលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះក្រៅតំបន់ ដែលតម្រូវការសម្រាប់ការចុះឈ្មោះក្រៅក្នុងតំបន់ លើសពីចំនួនកន្លែងដែលមាននៅក្រោមកម្រិតការចុះឈ្មោះចូលរៀន។**

ប្រសិនបើអ្នកកំពុងស្វែងរកទីកន្លែងរៀននៅសាលារៀនក្រៅតំបន់ សូមផ្តល់ហេតុផលនានាចំពោះការស្វែងរកទីកន្លែងរៀនក្រៅតំបន់ ឧទាហរណ៍៖

- បងប្អូនប្រុសស្រីដែលបានចុះឈ្មោះចូលរៀនរួចហើយ នៅសាលារៀន
- ភាពនៅជិត ឬលទ្ធភាពទៅមកសាលារៀន
- លទ្ធភាពដើម្បីទៅសាលារៀនសម្រាប់សិស្សតែមួយភេទ
- ហេតុផលវេជ្ជសាស្ត្រ
- សុវត្ថិភាព និងការត្រួតពិនិត្យកូនរបស់អ្នកមុន និងក្រោយសាលា
- ភាពអាចរកបាននៃមុខវិជ្ជា ឬការរួមបញ្ចូលគ្នានៃមុខវិជ្ជានៅសាលារៀន
- កាលៈទេសៈប្រកបដោយក្តីមេត្តា
- រចនាសម្ព័ន្ធ និងការរៀបចំរបស់សាលារៀន
- ការផ្លាស់ប្តូរថ្មីៗក្នុងព្រំដែនតំបន់ទទួលយកសិស្សក្នុងមូលដ្ឋាន។

ក្រុមជ្រើសរើសការចុះឈ្មោះចូលរៀនរបស់សាលា នឹងពិចារណាលើព័ត៌មាននៅលើទម្រង់បែបបទនេះ និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលអ្នកផ្តល់ជូនតែប៉ុណ្ណោះ។

ប្រសិនបើកូនរបស់អ្នកមិនបានទទួលទីកន្លែងរៀន នៅសាលារៀនស្របតាមជម្រើសទី 1 របស់អ្នកទេ កូនរបស់អ្នកនឹងត្រូវបានពិចារណាសម្រាប់ទីកន្លែងរៀនស្របតាមជម្រើសទី 2 របស់អ្នក បន្ទាប់មកជម្រើសទី 3 របស់អ្នក ប្រសិនបើអនុវត្ត។

ប្រសិនបើអ្នកមិនបានជោគជ័យក្នុងការទទួលបានទីកន្លែង រៀនមួយក្នុងចំណោមជម្រើសរបស់អ្នកទេ សាលារៀននឹងជូនដំណឹងមកអ្នក។ សាលារៀនអាចបង្ហាញថាអ្នកត្រូវបានដាក់ក្នុងបញ្ជីរង់ចាំមួយ ហើយអ្នកនឹងត្រូវបានផ្តល់ទីកន្លែងរៀនមួយ ប្រសិនបើមានកន្លែងទំនេរ។

ប្រសិនបើកូនរបស់អ្នកបានទទួលទីកន្លែងរៀនមួយ ពីចំណង់ចំណូលចិត្តនៃសាលារៀនដែលចុះក្នុងបញ្ជីរបស់អ្នក អ្នកនឹងមិនទទួលបានទីកន្លែងរៀនពីសាលារៀនណាមួយផ្សេងទៀត ដែលមានចំណង់ចំណូលចិត្តក្រោមនោះឡើយ។

ប្រសិនបើពុំមានទីកន្លែងទំនេរនៅសាលារៀនណាមួយដែលអ្នកបានស្នើសុំនោះទេ កូនរបស់អ្នកនឹងត្រូវបានរក្សាទុកនៅសាលារៀនក្នុង មូលដ្ឋានដែលបានចុះបញ្ជីនៅក្នុង**ផ្នែក B** ផ្អែកលើការទទួលយកពាក្យស្នើសុំរបស់អ្នក ដើម្បីចុះឈ្មោះចូលរៀនដោយសាលារៀននោះ។

ប្រសិនបើអ្នកគិតថាគេមិនប្រព្រឹត្តចំពោះអ្នកដោយយុត្តិធម៌ ឬគិតថាលទ្ធផលនោះមិនសមហេតុសមផល អ្នកអាចដាក់ពាក្យសុំប្តឹងជំទាស់។ បណ្តឹងជំទាស់នេះគួរតែបានធ្វើឡើងជាលាយលក្ខណ៍អក្សរទៅនាយកសាលាមធ្យមសិក្សា។

## ផ្នែក D

**ប្រសិនបើអ្នកបានដាក់ពាក្យសុំចូលរៀននៅសាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា** សូមគូសយកប្រអប់ក្នុង**ផ្នែក D** នៃទម្រង់បែបបទនេះ ហើយបំពេញ**ផ្នែក B, C** ឬ**ផ្នែក E** ក្នុងករណីកូនរបស់អ្នកមិនបានជោគជ័យក្នុងការទទួលបានទីកន្លែងនៅសាលាសម្រិតសម្រាំងសិស្ស។

## ផ្នែក E

**ប្រសិនបើអ្នកមិនតម្រូវទីកន្លែងរៀននៅសាលារៀនរដ្ឋទេ សូមបំពេញផ្នែក E។**

ការបំពេញចប់**ផ្នែក E** នឹងបិទរាល់សកម្មភាពទាំងអស់ដោយសាលារៀនរដ្ឋក្នុងរដ្ឋ NSW ដែលទាក់ទិននឹងការផ្តល់ទីកន្លែងរៀនរបស់កូនអ្នកនៅ Year 7។



ក្រសួងអប់រំរដ្ឋ NSW

# ការបង្ហាញចំណាប់អារម្មណ៍ (Expression of Interest)

ការផ្តល់ទីកន្លែងរៀន Year 7 នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW
Placement in Year 7 in a NSW Government school.

សូមបំពេញទម្រង់បែបបទនេះជាភាសាអង់គ្លេស។

**SRN** ☐☐☐☐☐☐☐☐☐

សម្រាប់តែការិយាល័យប្រើប៉ុណ្ណោះ (ឪពុកម្តាយ អ្នកថែទាំសូមកុំបំពេញ) (Office use only)

## A. ព័ត៌មានអំពីសិស្ស (A. Student information)

**នាមត្រកូល**
**Family name**

**នាមខ្លួន**
**First given name**

**ឈ្មោះ / ឈ្មោះកណ្តាល (ផ្សេងទៀត)**
**Middle (other) name/s**

**ភេទ** **Gender** ☐ **ប្រុស** Male ☐ **ស្រី** Female

**ថ្ងៃខែឆ្នាំកំណើត**
**Date of birth** ☐☐/☐☐/☐☐☐☐
*ថ្ងៃ* *ខែ* *ឆ្នាំ*

**អាសយដ្ឋានរស់នៅ** (*ឧទាហរណ៍ 1 High Street, Sydney, NSW, 2000*) **(Residential address)**

**ឈ្មោះឪពុកឬម្តាយ / អ្នកថែទាំសិស្ស**
**Name of parent/carer**

**លេខទូរសព្ទ** *(ដៃ)*
**Phone number** *(mobile)*

**លេខទូរសព្ទ** *(ផ្ទះ)*
**Phone number** *(home)*

***លេខទូរសព្ទ*** *(កន្លែងធ្វើការ)*
**Phone number** *(work)*

**អាសយដ្ឋានអ៊ីមែល**
**Email address**

**សាលាបឋមសិក្សាបច្ចុប្បន្នរបស់សិស្ស (Student's current primary school)**

**សេចក្តីប្រកាស (Declaration)**

ខ្ញុំសូមប្រកាសថា ព័ត៌មានដែលផ្តល់ក្នុងការបង្ហាញចំណាប់អារម្មណ៍នេះ តាមដែលខ្ញុំដឹង ហើយជឿជាក់ច្បាស់បំផុតថាមានភាពជាក់លាក់ និងពេញលេញ។ ខ្ញុំសូមទទួលស្គាល់ថា សេចក្តីប្រកាសក្នុងពាក្យសុំនេះ ប្រសិនបើថ្ងៃក្រោយបង្ហាញឱ្យឃើញថាមិនពិត ឬនាំឱ្យយល់ខុស ការសម្រេចចិត្តទាំងឡាយដែលបានធ្វើឡើងតាមពាក្យសុំនេះអាចត្រូវបានបដិសេធ។ ខ្ញុំយល់ដឹងថាការចុះឈ្មោះចូលរៀនណាមួយបន្ទាប់ពីដំណើរការផ្តល់ទីកន្លែងរៀន នឹងអាស្រ័យលើការពិចារណា និងការព្រមទទួលយកពាក្យសុំចុះឈ្មោះចូលរៀននៅសាលារៀនរដ្ឋក្នុងរដ្ឋ *NSW (Application to Enrol in a NSW Government School)*។

**ហត្ថលេខារបស់ឪពុកឬម្តាយ / អ្នកថែទាំសិស្ស (Signature of parent/carer)**

**សរសេរឈ្មោះជាអក្សរពុម្ព (Print name)**

**កាលបរិច្ឆេទ**
**Date** ☐☐/☐☐/☐☐☐☐
*ថ្ងៃ* *ខែ* *ឆ្នាំ*

## B. ការផ្តល់ទីកន្លែងរៀននៅសាលារៀនរដ្ឋក្នុងមូលដ្ឋាន (B. Placement at local government school)

**សាលារៀនក្នុងមូលដ្ឋានរបស់អ្នក (Your local school)**

ប្រសិនបើមានសាលារៀនក្នុងមូលដ្ឋានដែលបានកំណត់ចំនួនពីរ ដែលអាចផ្តល់ឱ្យកូនរបស់អ្នក សូមគូសរង្វង់ជុំវិញសាលារៀនដែលអ្នកចង់ឱ្យកូនរបស់អ្នកទៅរៀន៖

**ហត្ថលេខារបស់ឪពុកឬម្តាយ / អ្នកថែទាំសិស្ស (Signature of parent/carer)**

**កាលបរិច្ឆេទ**
**Date** ☐☐/☐☐/☐☐☐☐
*ថ្ងៃ* *ខែ* *ឆ្នាំ*

ប្រសិនបើអ្នកបានចុះហត្ថលេខាខាងលើ ហើយចង់ឱ្យកូនរបស់អ្នកចូលរៀននៅសាលារៀននេះ **តែប៉ុណ្ណោះ** ឥឡូវនេះអ្នកបានបំពេញទម្រង់បែបបទហើយ។

## C. ការពិចារណាដើម្បីផ្តល់ទីកន្លែងរៀន នៅសាលារៀនរដ្ឋផ្សេងទៀត
## C. Consideration to be given to placement at other government schools

**ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចូលរៀននៅសាលារៀនក្រៅមូលដ្ឋាន អ្នកអាចផ្តល់ចំណង់ចំណូលចិត្តអតិបរមាចំនួនបី។ អ្នកអាចរួមបញ្ចូល៖**

- **សាលាឯកទេសរដ្ឋ។** សូមកត់សម្គាល់ថា អ្នកត្រូវបានលើកទឹកចិត្តឱ្យស្វែងរកជំនួយពីនាយកសាលាបឋមសិក្សា ប្រសិនបើអ្នកប្រាថ្នាចង់ឱ្យកូនរបស់អ្នកត្រូវបានពិចារណាសម្រាប់ការផ្តល់ទីកន្លែងរៀននៅសាលាឯកទេសរដ្ឋ។
- សាលារៀនដែលមាន**ថ្នាក់គាំទ្រ** ដើម្បីផ្គត់ផ្គង់ដល់សិស្សដែលមានតម្រូវការរៀនសូត្រ និងជំនួយបន្ថែម។ សូមកត់សម្គាល់ថា នេះត្រូវបានធ្វើឡើងតាមរយៈក្រុមផ្តល់ទីកន្លែងរៀន។ **អ្នកគួរតែស្វែងរកជំនួយពីនាយកសាលាបឋមសិក្សា ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកត្រូវបានពិចារណាសម្រាប់ការផ្តល់ថ្នាក់គាំទ្រ។**
- សាលារៀនរដ្ឋ**ក្រៅមូលដ្ឋាន**ផ្សេងទៀត។ សូមបញ្ជាក់ពីហេតុផលនានារបស់អ្នក សម្រាប់ការស្វែងរកកន្លែងរៀនក្រៅមូលដ្ឋាន នៅផ្នែកខាងក្រោមនៃទំព័រនេះ (និងនៅទំព័រ 7 ប្រសិនបើតម្រូវ)។

ខ្ញុំប្រាថ្នាស្វែងរកកន្លែងរៀនសម្រាប់កូនរបស់ខ្ញុំ នៅសាលារៀនរដ្ឋដូចខាងក្រោម៖

| | |
|---|---|
| **ឈ្មោះសាលារៀនជម្រើសទី 1; Choice 1 school** | |
| **ឈ្មោះសាលារៀនជម្រើសទី 2; Choice 2 school** | |
| **ឈ្មោះសាលារៀនជម្រើសទី 3; Choice 3 school** | |

ខ្ញុំដឹងថា ប្រសិនបើកូនរបស់ខ្ញុំពុំបានជោគជ័យក្នុងការទទួលបានកន្លែងរៀននៅសាលារៀនមួយ ក្នុងចំណោមសាលារៀនដូចខាងលើនេះទេ កូនរបស់ខ្ញុំនឹងត្រូវបានដាក់នៅសាលារៀនក្នុងមូលដ្ឋានដែលបានកំណត់ដូចមានរាយឈ្មោះក្នុងផ្នែក B។

**ហត្ថលេខារបស់ឪពុកឬម្តាយ / អ្នកថែទាំសិស្ស (Signature of parent/carer)**

**កាលបរិច្ឆេទ Date** __ __ / __ __ / __ __ __ __
*ថ្ងៃ ខែ ឆ្នាំ*

## សម្រាប់តែនាយកសាលាបឋមសិក្សាប្រើប៉ុណ្ណោះ (Primary school principal use only)

Primary school principals may wish to include comments to assist secondary school principals make placement decisions. These comments should refer to the reasons given by parents and carers.

**Signature of primary school principal**

**Date** __ __ / __ __ / __ __ __ __
*day month year*

**បំពេញព័ត៌មានខាងក្រោមនេះតែប៉ុណ្ណោះ ប្រសិនបើអ្នកដាក់ពាក្យសុំកន្លែងរៀននៅសាលារៀនក្រៅមូលដ្ឋាន។ អ្នកមិនចាំបាច់បំពេញផ្នែកនេះទេ ប្រសិនបើអ្នកដាក់ពាក្យសុំសាលាឯកទេស ឬថ្នាក់គាំទ្រ។**
ប្រសិនបើចាំបាច់ អ្នកអាចភ្ជាប់ជាមួយនូវព័ត៌មានបន្ថែម ដើម្បីជួយគាំទ្រដល់ការស្នើសុំកន្លែងរៀនរបស់អ្នកនៅសាលារៀនក្រៅមូលដ្ឋាន។ ដើម្បីទទួលបានព័ត៌មានបន្ថែម សូមយោងទៅទំព័រ 2 និង 3។

**ឈ្មោះសាលារៀនជម្រើសទី 1: Name of Choice 1 school**

សូមគូសបញ្ជាក់ពីហេតុផលនានារបស់អ្នក ចំពោះការស្វែងរកការដាក់ទីកន្លែងរៀននៅសាលារៀននេះ (សូមយោងទៅលក្ខណៈវិនិច្ឆ័យជាក់លាក់ដើម្បីចុះឈ្មោះចូលរៀនរបស់សាលារៀន)។

## C. 'បន្ត' C. (continued)

**ឈ្មោះសាលារៀនជម្រើសទី 2:**
**Name of Choice 2 school** ____________________

សូមគូសបញ្ជាក់ពីហេតុផលនានារបស់អ្នក ចំពោះការស្វែងរកការដាក់ទីកន្លែងរៀននៅសាលារៀននេះ (សូមយោងទៅលក្ខណៈវិនិច្ឆ័យដាក់លាក់ដើម្បីចុះឈ្មោះចូលរៀនរបស់សាលារៀន)។

____________________

____________________

____________________

____________________

**ឈ្មោះសាលារៀនជម្រើសទី 3:**
**Name of Choice 3 school** ____________________

សូមគូសបញ្ជាក់ពីហេតុផលនានារបស់អ្នក ចំពោះការស្វែងរកការដាក់ទីកន្លែងរៀននៅសាលារៀននេះ (សូមយោងទៅលក្ខណៈវិនិច្ឆ័យដាក់លាក់ដើម្បីចុះឈ្មោះចូលរៀនរបស់សាលារៀន)។

____________________

____________________

____________________

____________________

## D. សាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា (D. Academically selective school)

☐ ខ្ញុំបានដាក់ពាក្យសុំការដាក់ទីកន្លែងរៀននៅសាលាសម្រិតសម្រាំងសិស្សដោយផ្អែកលើការសិក្សា។ កូនរបស់ខ្ញុំនឹងអង្គុយធ្វើតេស្តសុំចូលរៀនសាលាមធ្យមសិក្សាសម្រិតសម្រាំងសិស្ស។
I have submitted an application for placement in an academically selective school. My child will be sitting for the Selective High Schools test.

*ក្នុងករណីដែលកូនរបស់អ្នកពុំបានជោគជ័យក្នុងការទទួលបានទីកន្លែងរៀននៅសាលារៀននេះ/ទាំងនេះ សូមបំពេញផ្នែក B, ផ្នែក C ឬផ្នែក E នៅក្នុងទម្រង់បែបបទនេះ។*

## E. ពុំត្រូវការដាក់ទីកន្លែងរៀន (E. Placement not required)

ខ្ញុំសូមបញ្ជាក់ថា កូនរបស់ខ្ញុំនឹងមិនស្វែងរកទីកន្លែងរៀននៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW នៅឆ្នាំក្រោយនេះទេ។ ខ្ញុំបានអាន និងយល់ដឹងព័ត៌មានអំពីការដាក់បញ្ជូននេះ រួមទាំងការប្រមូលព័ត៌មានផ្ទាល់ខ្លួន។ កូនរបស់ខ្ញុំនឹងចូលរៀននៅសាលារៀនដូចខាងក្រោម។*
I confirm that my child will not be seeking placement at a NSW Government school next year. I have read and understood the information about this submission including the collection of personal information. My child will be attending the following school.*

____________________

**ហត្ថលេខារបស់ឪពុកឬម្ដាយ/អ្នកថែទាំសិស្ស (Signature of parent/carer)**

____________________

**កាលបរិច្ឆេទ**
**Date** ☐☐ / ☐☐ / ☐☐☐☐
*ថ្ងៃ ខែ ឆ្នាំ*

***ការផ្ដល់ព័ត៌មាននេះពុំបានតម្រូវជាចាំបាច់ឡើយ ក៏ប៉ុន្តែយើងសូមអរគុណអ្នក ប្រសិនបើអ្នកបានផ្ដល់ព័ត៌មាននេះ។**

### សេចក្ដីប្រកាសអំពីភាពឯកជន (Privacy Statement)

ព័ត៌មានផ្ទាល់ខ្លួនដែលបានផ្ដល់នៅលើទម្រង់បែបបទនេះ ដែលមានចំណងជើងថា **ការបង្ហាញចំណាប់អារម្មណ៍ - ការផ្ដល់ទីកន្លែងរៀន Year 7** នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW កំពុងត្រូវបានប្រមូលសម្រាប់គោលបំណងនៃការសម្របសម្រួលការដាក់ពាក្យសុំចុះឈ្មោះចូលរៀន Year 7 ដែលមានសក្ដានុពល នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW។ រាល់ព័ត៌មានដែលផ្ដល់ទៅឱ្យក្រសួងអប់រំរដ្ឋ NSW (**ក្រសួង**) នឹងត្រូវបានប្រើប្រាស់ លាតត្រដាង និងរក្សាទុកស្របតាមច្បាប់ឯកជនភាពរដ្ឋ NSW។

ព័ត៌មានមួយចំនួនត្រូវបានទាមទារដោយ**ក្រសួង** ដើម្បីបំពេញកាតព្វកិច្ចក្នុងការថែទាំ និងកាតព្វកិច្ចផ្លូវច្បាប់ផ្សេងទៀត ហើយនិងមុខងារនានាក្រោមច្បាប់សុខភាពសាធារណៈ ការអប់រំ និងការការពារកុមារ និងដើម្បីពេញតម្រូវការប្រមូលទិន្នន័យ និងរបាយការណ៍ក្រោមកិច្ចព្រមព្រៀងមូលនិធិសហព័ន្ធ - រដ្ឋ។ ទាំងនេះអាចពាក់ព័ន្ធនឹងការប៉ាន់ប្រមាណ និងការវាយតម្លៃលទ្ធផលសិក្សាសិស្ស។

ព័ត៌មានអាចត្រូវបានលាតត្រដាងដល់ទីភ្នាក់ងាររដ្ឋាភិបាលរដ្ឋ NSW និងសហព័ន្ធ និងអង្គការផ្សេងទៀត សម្រាប់គោលបំណងខាងលើ និងតាមការអនុញ្ញាត ឬតម្រូវដោយច្បាប់។

ព័ត៌មាននឹងត្រូវបានរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យអេឡិចត្រូនិចដែលមានសុវត្ថិភាព។ អ្នកអាចចូលប្រើប្រាស់ ឬកែតម្រូវព័ត៌មានដោយទាក់ទងទៅសាលារៀនរបស់កូនអ្នក។ ប្រសិនបើអ្នកមានការព្រួយបារម្ភ ឬបណ្ដឹងតវ៉ាណាមួយអំពីព័ត៌មានដែលប្រមូលបាន ឬរបៀបដែលវាត្រូវបានប្រើប្រាស់ ឬលាតត្រដាង អ្នកគួរតែទាក់ទងមកសាលារៀន។

ប្រសិនបើអ្នកជ្រើសរើសមិនផ្ដល់ព័ត៌មានដែលបានស្នើសុំមួយចំនួនទេនោះ វាអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការចុះឈ្មោះរបស់កូនអ្នក ការផ្ដល់ធនធានរបស់សាលារៀន ឬការបំពេញតម្រូវការអប់រំរបស់កូនអ្នក។

ព័ត៌មានបន្ថែមអំពីការប្រមូលព័ត៌មាន ខណៈពេលដែលកូនរបស់អ្នកបានចុះឈ្មោះចូលរៀននៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW និងរបៀបដែលយើងការពារឯកជនភាពរបស់អ្នក អាចរកបាននៅតាមគេហទំព័ររបស់ក្រសួង ឬពីសាលារៀនរបស់អ្នក។ អ្នកអាចទទួលបានច្បាប់ចម្លងនៃសេចក្ដីជូនដំណឹងអំពីការប្រមូលឯកជនភាពរបស់ក្រសួង នៅតាមគេហទំព័រ https://education.nsw.gov.au/content/dam/main-education/about-us/rights-and-accountability/media/documents/privacy/collection-notice.pdf

សម្រាប់សិស្សដែលបច្ចុប្បន្នបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សារដ្ឋ សូមប្រគល់ទម្រង់បែបបទនេះទៅឱ្យទៅសាលាបឋមសិក្សារបស់កូនអ្នកវិញ។ សម្រាប់សិស្សដែលមិនបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សារដ្ឋ សូមប្រគល់ទម្រង់បែបបទនេះទៅឱ្យសាលាមធ្យមសិក្សារដ្ឋវិញ ដែលជាចំណង់ចំណូលចិត្តទីមួយរបស់អ្នកសម្រាប់ការចុះឈ្មោះចូលរៀន។ **រាល់ការបង្ហាញចំណាប់អារម្មណ៍ត្រូវតែបានប្រគល់មកវិញឱ្យបានទាន់ ឬមុនកាលបរិច្ឆេទផុតកំណត់។**



យើងទទួលស្គាល់ប្រទេសកំណើតរបស់ជនជាតិដើម Aboriginal ទាំងអស់ និងសម្តែងការគោរពចំពោះទឹកដីនេះ។


**Say hello**

@NSWDepartmentofEducation

@NSWEducation

@NSWEducation

education.nsw.gov.au



© 2023 NSW Department of Education



GPO Box 33, Sydney NSW 2001 Australia

Phone: 1300 679 332